**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានឃើញប្រកាសលេខ២២៧ ក.ប/ប្រ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ ..**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា «វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង» ឈ្មោះជាភាសាអង់គ្លេស «Vanda Institute of Battambang» សរសេរកាត់ជាភាសាខ្មែរ «វវដ-បប» និងសរសេរកាត់ជាភាសាអង់គ្លេស «VI-BB»។

**មាត្រា២ ..**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានទីតាំងស្ថិតនៅដីឡូត៍លេខ២៧១ ផ្លូវលេខ៦១៤ ភូមិរំចេក២ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ ..**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានភារកិច្ចធ្វើការបណ្តុះបណ្តាលៈ

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ០២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ០៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកសាខា ដេប៉ាតឺម៉ង់ មហាវិទ្យាល័យ ដំឡើងកម្រិត ប្តូរទីតាំងឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ ..**

វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ ..**

នាយកវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង មានភារកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្សឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពតាមវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀងទាត់តាមការកំណត់។

**មាត្រា៦ .-**

សិស្ស-និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រ តាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ដោយវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ដែលមានការទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថានបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ .-**

ប្រកាសលេខ២២៧ ក.ប/ប្រ.ក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់វិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថាន វ៉ាន់ដាបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ